**សេចក្តីជូនដំណឹងសំខាន់**



សម្រាប់គ្រួសារដែលមិនមែនមានតែឪពុកឬម្តាយ (ដែលបានទទួលប្រាក់ឧបត្ថម្ភលើកនេះរួចហើយ)

# សេចក្តីណែនាំស្តីអំពីប្រាក់ឧបត្ថម្ភពិសេសសម្រាប់គាំទ្រជីវភាពគ្រួសារដែលមានកូនក្នុងបន្ទុក

**កម្មវិធីផ្តល់ជូនប្រាក់ឧបត្ថម្ភថ្មី** សម្រាប់គាំទ្រដល់គ្រួសារដែលមានកូនក្នុងបន្ទុក!

## ១. អ្នកដែលអាចទទួលបាន

អ្នកដែលបំពេញទាំងលក្ខខណ្ឌ①② (*លើកលែងអ្នកដែលបានទទួលប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារដែលមានតែឪពុកឬម្តាយរួចហើយ)

① គិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
ឪពុកម្តាយដែលកំពុងចិញ្ចឹម**កូនដែលមានអាយុក្រោម១៨ឆ្នាំ** (**ក្រោម២០ឆ្នាំ** សម្រាប់កុមារពិការ)
(*ទារកដែលទើបកើតត្រឹមចុង ខែកុម្ភៈ ឆ្នាំ២០២២ ក៏រាប់បញ្ចូលផងដែរ។)

② ◎អ្នកដែល**ត្រូវបានលើកលែងពន្ធស្នាក់នៅ (អត្រានៃមនុស្សម្នាក់)** សម្រាប់ ឆ្នាំ២០២១ ឬ
◎អ្នកដែលមានចំណូលថយចុះខ្លាំងចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ហើយត្រូវបានចាត់ទុកជាអ្នកមានប្រភេទចំណូលដែលសមស្របសម្រាប់**ការលើកលែងពន្ធស្នាក់នៅ**

## ២. ទឹកប្រាក់ឧបត្ថម្ភ

**៥ ម៉ឺន យ៉េន ស្មើៗគ្នា ក្នុងកុមារម្នាក់**

◎នៅក្នុងការឧបត្ថម្ភ មាន<u>ករណីដែលមិនចាំបាច់ដាក់ពាក្យ</u>និង<u>ករណីដែលត្រូវការដាក់ពាក្យ</u>។
សូមប្រាកដថាបានពិនិត្យមើលពីនីតិវិធីក្នុងការដាក់ពាក្យនៅទំព័រខាងក្រោយ។

*សម្រាប់ការសាកសួរព័ត៌មាន សូមទូរសព្ទមកកាន់លេខខាងក្រោម។

◎មជ្ឈមណ្ឌលទូរសព្ទ របស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព

**០១២០-៨១១-១៦៦** (ម៉ោងទទួលទូរសព្ទ៖ ថ្ងៃធ្វើការ ៩:០០ ដល់ ១៨:០០)

សម្រាប់ព័ត៌មានលម្អិតក្នុងការដាក់ពាក្យ សូមសាកសួរទៅកាន់ "ការិយាល័យទទួលបន្ទុកប្រាក់ឧបត្ថម្ភពិសេសសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារដែលមានកូនក្នុងបន្ទុក(លើកលែងគ្រួសារដែលមានតែឪពុក ឬម្តាយតែមួយ)" នៅតាមភូមិឃុំដែលអ្នកកំពុងស្នាក់នៅ។

## ៣. នីតិវិធីក្នុងការដាក់ពាក្យទទួលប្រាក់ឧបត្ថម្ភ

**I អ្នកដែលបានទទួលប្រាក់បន្ថែមសម្រាប់កុមារ ឬ ប្រាក់ឧបត្ថម្ភចិញ្ចឹមកូនពិសេសសម្រាប់កុមារ សម្រាប់ខែមេសា ឆ្នាំ២០២១ ហើយជាអ្នកដែលត្រូវបានលើកលែងពន្ធស្នាក់នៅ**

◎អាចទទួលបានប្រាក់ឧបត្ថម្ភ ដោយ**មិនចាំបាច់ដាក់ពាក្យ**។

◎នៅតាមភូមិឃុំនីមួយៗ យើងនឹងផ្ទេរប្រាក់បន្ថែមសម្រាប់កុមារ ឬប្រាក់ឧបត្ថម្ភចិញ្ចឹមកូនពិសេសសម្រាប់កុមារ សម្រាប់ខែមេសា ឆ្នាំ២០២១ ទៅកាន់គណនីដែលបានកំណត់ ឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។

«សូមប្រុងប្រយ័ត្ន»

* ប្រសិនបើអ្នកមិនមានបំណងចង់ទទួលប្រាក់ឧបត្ថម្ភទេ សូមផ្ញើឯកសារបដិសេធទទួលប្រាក់ឧបត្ថម្ភ។
* ប្រសិនបើអ្នកបានបិទគណនីដែលបានកំណត់សម្រាប់ទទួលប្រាក់បន្ថែមសម្រាប់កុមារ ឬ ប្រាក់ឧបត្ថម្ភចិញ្ចឹមកូនពិសេសសម្រាប់កុមារ នោះវាអាចនឹងមានបញ្ហាកើតឡើងនៅពេលផ្ទេរប្រាក់ឧបត្ថម្ភចូល ដូច្នេះសូមធ្វើបែបបទប្ដូរគណនីទទួលប្រាក់បន្ទេរជាដើម។

**II.សម្រាប់អ្នកផ្សេងពីករណីខាងលើ** (ឧទាហរណ៍ អ្នកដែលចិញ្ចឹមតែកូនដែលជាសិស្សវិទ្យាល័យ ឬអ្នកដែលមានចំណូលថយចុះខ្លាំង)

◎ដើម្បីទទួលបានប្រាក់ឧបត្ថម្ភ **ចាំបាច់ត្រូវការដាក់ពាក្យ**។

◎សូមបំពេញលេខគណនីទទួលប្រាក់បន្ទេរនៅលើបែបបទដាក់ពាក្យ រួចភ្ជាប់មកជាមួយនូវឯកសារចាំបាច់ ហើយយកទៅ**ដោយផ្ទាល់** ឬផ្ញើ ទៅកាន់**ការិយាល័យ**នៅតាមភូមិឃុំដែលអ្នកកំពុងស្នាក់នៅ។

◎យើងនឹងធ្វើការពិនិត្យខ្លឹមសារនៅក្នុងបែបបទ ចំពោះអ្នកបានបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ទទួលប្រាក់ឧបត្ថម្ភ រួចនឹងផ្ទេរប្រាក់ឧបត្ថម្ភទៅកាន់គណនីដែលបានកំណត់។




**!** សូមប្រុងប្រយ័ត្នចំពោះ **"ការក្លែងបន្លំការផ្ទេរប្រាក់" ឬ "ការបោកប្រាស់យកព័ត៌មានផ្ទាល់ខ្លួន"** ទាក់ទងនឹងកម្មវិធី "ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារដែលមានកូនក្នុងបន្ទុក"

ប្រសិនបើមានការទូរសព្ទចូល ឬបញ្ញើប្រៃសណីយចម្លែកដែលតាំងខ្លួនជាអាជ្ញាធរភូមិឃុំស្រុកខេត្ត ឬ(បុគ្គលិករបស់)ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព មកកាន់គេហដ្ឋានឬកន្លែងធ្វើការ សូមទាក់ទងទៅកាន់ប៉ុស្តិ៍ប៉ូលិសដែលនៅតាមភូមិឃុំដែលអ្នកកំពុងស្នាក់នៅ ឬដែលនៅជិតបំផុត ឬទាក់ទងទៅកាន់ទូរសព្ទពិគ្រោះយោបល់របស់ស្ថាប័នប៉ូលិស(#៩១១០)។